របាយការណ៍ប្រចាំឆ្នាំ
២០២០



ahc

Angkor Hospital for Children

# 2020 ANNUAL REPORT

## 21 Years of Transforming Paediatric Healthcare

angkorhospital.org

# មាតិកា

# Table of Contents


សាររបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យកុមារអង្គរ 6
Leadership Message

តួលេខឆ្នាំ២០២០ 8
2020 in Numbers

សូចនាករនៃការអនុវត្តការងារ 14
Key Perfomance Indicators

ជម្នះបញ្ហាលំបាក 18
Overcoming Adversity

សម្លេងនៃភាពរឹងមាំ 26
Stories of Resilience

អភិបាលកិច្ច 50
Governance

របាយការណ៍ហិរញ្ញវត្ថុ 52
Financials

សេចក្តីថ្លែងអំណរគុណ 54
Thank You




# សាររបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យកុមារអង្គរ

# Leadership Message



## ឆ្នាំ២០២០ គឺជាឆ្នាំដ៏លំបាកមួយ ប៉ុន្តែវាជាភស្តុតាង ដែលបង្ហាញពីភាពរឹងមាំរបស់មន្ទីរពេទ្យកុមារអង្គរ

ក្នុងខណៈពេលដែលវិបត្តិនៃជំងឺរាតត្បាត
ជាសកលបានផ្លាស់ប្តូរពិភពលោកទាំងមូល
និងបរិបទនៃការងាររបស់យើងទាំងអស់គ្នា
ចក្ខុវិស័យគ្រឹះរបស់យើងគឺត្រូវបានរក្សានៅ
ដដែល៖ កុមារគ្រប់រូបមានសិទ្ធិទទួលបាន
សេវាថែទាំសុខភាពប្រកបដោយគុណភាព
ខ្ពស់ និងសេចក្តីមេត្តាករុណា ។
នេះគឺជាការពិតជាងពេលណាទាំងអស់។
ប្រទេសកម្ពុជាបានឆ្លងផុតឆ្នាំ២០២០ ដោយ
មិន រងផលប៉ះពាល់ធ្ងន់ធ្ងរនៃជំងឺរាតត្បាតកូ
វីដ ១៩ នេះទេ ដោយឡែក មន្ទីរពេទ្យកុមារ
អង្គរបានមើលឃើញពីឥទ្ធិពល និងផល
ប៉ះពាល់ប្រយោលនៃវិបត្តិមួយនេះមកលើ
ប្រជាពលរដ្ឋកម្ពុជា។
ការកើនឡើងនៃជំងឺកង្វះអាហារូបត្ថម្ភ
តម្រូវការនៃការអប់រំអំពីការការពារសុខភាព
ភាពយឺតយ៉ាវនៃការស្វែងរកសេវាថែទាំ
សុខភាព និងផលប៉ះពាល់មួយចំនួនទៀត
នៃជំងឺកូវីដ១៩ ជាកត្តាធ្វើឱ្យយើង
កាន់តែខិតខំប្រឹងប្រែងបំពេញតួនាទីដ៏មាន
សារៈសំខាន់ ដើម្បីធានាថាកុមារគ្រប់រូបទទួល
បាននូវការយកចិត្តទុកដាក់ផ្នែកសុខភាពដែល
ពួកគេត្រូវការ។
ក្នុងឆ្នាំខាងមុខ បញ្ហាប្រឈម នឹងកើតមាន
ឡើង រួមមានវិបត្តិសេដ្ឋកិច្ចដោយសារ
ជំងឺរាតត្បាត និងផលវិបាកដែលអាច
ប៉ះពាល់ទៅលើសុខុមាលភាពរបស់កុមារ។
ទោះជាយ៉ាងនេះក៏ដោយ ក៏យើងនៅតែមាន
សុទិដ្ឋិនិយម ចំពោះសមត្ថភាពរបស់យើង
នៅក្នុងការប្រឈមទៅនឹងបញ្ហាទាំងនេះ។
ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក្នុងប្រទេសមាន
ភាពល្អប្រសើរ។ ចាប់តាំងពីការកើតឡើងដំបូងនៃ
ជំងឺរាតត្បាតនេះ ប្រទេសកម្ពុជាបានអនុវត្តតាម
គោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលយ៉ាង
ហ្មត់ចត់ហើយទទួលបានជោគជ័យក្នុងការទប់ស្កាត់ការ
ចម្លងនៃជំងឺនេះ។ ស្ថាប័នរដ្ឋ ដៃគូឯកជន និងអង្គការ
មិនមែនរដ្ឋាភិបាលបានធ្វើការរួមគ្នាដើម្បីបង្ការការរីក
រាលដាលនៃជំងឺកូវីដ១៩ នៅទូទាំងប្រទេស។
សមត្ថភាពផ្ទាល់របស់យើងក្នុងការកំណត់ទិសដៅ
ទុកជាមុន អនុញ្ញាតឱ្យមន្ទីរពេទ្យកុមារអង្គរនឹងបញ្ចប់
ឆ្នាំ២០២១ ប្រកបដោយភាពរឹងមាំតាមរយៈការរៀបចំ
ផែនការ ការការពារ និងការសម្របខ្លួន។
សូមថ្លែងអំណរគុណចំពោះការគាំទ្រដ៏ធំធេង និង
ប្រកបដោយទឹកចិត្តសប្បុរសរបស់ម្ចាស់ជំនួយ ដៃគូ
និងបុគ្គលិកស្ម័គ្រចិត្តទាំងអស់។ មន្ទីរពេទ្យកុមារ
អង្គរ បានយកឈ្នះលើឆ្នាំដ៏លំបាកនេះ ព្រមទាំង
បានឆ្លើយតបនឹងការលេចឡើងនៃតម្រូវការការថែទាំ
សុខភាពរបស់កុមារទាំងនៅក្នុងមន្ទីរពេទ្យ សហគមន៍
និងទីកន្លែងផ្សេងៗទៀត។ យើងនឹងបន្តកំណត់
អាទិភាពនូវរាល់បញ្ហាទាំងឡាយ ដែលបានកើតឡើង
នៅក្នុងទីកន្លែងដែលមានតម្រូវការចាំបាច់ និងដែល
អាចធ្វើឲ្យល្អប្រសើរបាន ព្រមទាំងកសាងសមត្ថភាព
សហគមន៍ និងបង្កើតជាគំរូអភិបាលកិច្ចល្អ។
សូមអរគុណដល់អ្នកទាំងអស់គ្នាសម្រាប់ការចូលរួមក្នុង
បេសកកម្មរបស់យើង។
សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ!

## 2020 proved to be a year of adversity – and proof of AHC's resilience.

As the global pandemic changed the world and the context in which we operate, we remained consistent in our founding vision: for all Cambodian children to have access to quality, compassionate medical care.

Never has this been truer than today. While Cambodia fortunately escaped 2020 without a full outbreak of COVID-19, here at AHC we saw the downstream impacts and the pandemic's indirect effects on families.

Increases in malnutrition, the need for preventative healthcare education, the delays in care-seeking, and other knock-on effects from COVID-19 led us to work harder to fill a critical role in ensuring every child received the care they needed.

Looking ahead, there will be a number of challenges, including the pandemic's economic impacts and the consequences they could cause in child health. Yet, we remain optimistic in our ability to meet these challenges.

The response to COVID-19 nationally has been promising. Since the pandemic's beginning, the country followed clear guidelines from the Ministry of Health, and succeeded in containing transmissions. Public, private and NGO partnerships worked together to prevent COVID-19 from spreading throughout the country.

Our own ability to pivot early on allowed AHC to finish 2020 strong, as we found ways to prepare, prevent and adapt.

Thanks to generous, essential support from donors, partners and volunteers like you, AHC was able rise to the year's adversities and respond to emerging child health needs, within our hospital, the community and beyond. We will continue to prioritise challenges where the greatest need exists and the most impact can be achieved, leading the way in providing specialty care available nowhere else, building capacity beyond our walls and embodying exemplary governance in our approach.

**Thank you for joining us in our mission.**

Gratefully,
**AHC Executive Committee**

Prof. Claudia Turner,
MB BS, PhD, FRCPCH
Chief Executive Officer

Ngoun Chanpheaktra,
MD, DCH, DTMH
Hospital Director

Robert Gazzi,
Board Chairman



# តួលេខឆ្នាំ២០២០

## 2020 in Numbers

**97, 069**

ចំនួននៃការព្យាបាលសរុប ដោយរាប់ចាប់ពីផ្នែកពិគ្រោះជំងឺក្រៅ
ដល់សេវាព្យាបាលឯកទេស

total treatments provided,
from outpatient care to specialty services

**73, 908**

ចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលនៅមន្ទីរពេទ្យកុមារអង្គរ ដោយរួមមានមន្ត្រីសុខាភិបាល
និស្សិតគិលានុបដ្ឋាក និស្សិតវេជ្ជសាស្ត្រ និងបុគ្គលិកមន្ទីរពេទ្យកុមារអង្គរ។

attendances recorded at AHC educational sessions,
including external healthcare professionals, nursing and
medical students, and AHC staff

**56, 747**

ចំនួនអ្នកចូលរួមសកម្មភាពអប់រំ ការពារនិងលើកកម្ពស់សុខភាពរបស់មន្ទីរពេទ្យកុមារអង្គរ
នៅក្នុងសហគមន៍ តាមបណ្តាភូមិ សាលារៀន មណ្ឌលសុខភាព និងក្នុងសហគមន៍ ។

attendances recorded at
AHC community prevention activities,
within villages, schools and communes



# តួលេខឆ្នាំ២០២០

## 2020 in Numbers

**1,334**

ចំនួនអ្នកជម្ងឺធ្ងន់ធ្ងរដែលបានទទួលការសង្គ្រោះជីវិតបន្ទាន់

intensive care patients received
emergency treatment for life-threatening conditions

**37**

ចំនួនមន្ត្រីសុខាភិបាលត្រូវបានពង្រឹងសមត្ថភាព

government health facilities strengthened

**6**

ចំនួនវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យកុមារអង្គរ ដែលបានបញ្ចប់ការសិក្សាឆ្នាំទី១ នៃកម្មវិធី
បណ្តុះបណ្តាលអាហារូបករណ៍រយៈពេល៣ឆ្នាំដើម្បីក្លាយទៅជាវេជ្ជបណ្ឌិតឯកទេសជំងឺកុមារ

doctors completed their first year
of their three-year fellowship training
programme to become a paediatric specialty doctor

# តួលេខឆ្នាំ២០២០
# 2020 in Numbers

ទិន្នន័យដែលប្រមូលបាននៅមន្ទីរពេទ្យកុមារអង្គរក្នុងឆ្នាំ២០២០ បង្ហាញពីអាកប្បកិរិយាក្នុងការស្វែងរកការថែទាំសុខភាពរបស់ក្រុមគ្រួសារអ្នកជំងឺ និង តួនាទីដ៏សំខាន់ សមត្ថភាពថែទាំកុមាររបស់មន្ទីរពេទ្យកុមារអង្គរក្នុងគ្រាលំបាកនេះ។ ភាពភ័យខ្លាចនៃការឆ្លងវីរុស ធ្វើឱ្យអាណាព្យាបាលជៀសវាង ឬពន្យាពេលក្នុងការស្វែងរកការថែទាំ ហើយនៅទីបំផុតធ្វើឱ្យជំងឺកាន់តែធ្ងន់ធ្ងរ។ រឿងរ៉ាវនេះ ត្រូវបានបង្ហាញតាមរយៈចំនួនបម្រែបម្រួលឡើងចុះនៃការពិនិត្យជំងឺនៅផ្នែកពិនិត្យជំងឺក្រៅក៏ប៉ុន្តែមានការកើនឡើងឬមានស្ថេរភាពនៅផ្នែកសម្រាកព្យាបាល ករណីនេះរួមមានផ្នែកសម្រាកព្យាបាល ផ្នែកជំងឺធ្ងន់ធ្ងរ និង ផ្នែកថែទាំទារក ដែលផ្នែកទាំងនោះមានអ្នកជំងឺស្ទើរតែពេញ ដែលមានជំងឺកម្រិតធ្ងន់ធ្ងរដល់អាយុជីវិត ឬក៏កំពុងត្រូវការការវះកាត់បន្ទាន់។

Data collected at AHC in 2020 shows the healthcare-seeking behaviour of parents, and AHC's critical role in paediatric care capacity during these times.

Fear of catching the virus resulted in avoidance of or delay in seeking care, eventually requiring more intensive care for advanced conditions. The story, told through numbers, showed fluctuations in outpatient visits, but stable and increased numbers for inpatient care. This included AHC's Inpatient Department (IPD), Paediatric Intensive Care Unit (PICU), and Special Care Baby Unit (SCBU), which all remained at near full capacity treating children and babies suffering from a range of life-threatening infectious diseases, or requiring emergency surgery and trauma care.

## 2020 Timeline






# សូចនាករនៃការអនុវត្តការងារ

# Key Performance Indicators

មន្ទីរពេទ្យកុមារអង្គរ វាស់ស្ទង់គុណភាព និងប្រសិទ្ធិភាពការងារតាមរយៈការពិនិត្យមើលលើសូចនាករនៃការអនុវត្តការងារនៅក្នុងផ្នែកនីមួយៗរបស់មន្ទីរពេទ្យ ដោយអនុលោមតាមក្រមប្រតិបត្តិអន្តរជាតិល្អបំផុត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ផ្នែកវេជ្ជសាស្ត្រ និងលទ្ធផលនៃការថែទាំសុខភាព។

AHC measures quality and effectiveness by monitoring Key Performance Indicators across departments, in line with international best practices, to improve clinical practice and health outcomes.

## កម្រិតអនាម័យដៃខ្ពស់បំផុត

នៅក្នុងឆ្នាំដែលការបង្ការ និងត្រួតពិនិត្យការចម្លងរោគមានសារៈសំខាន់ខ្លាំង មន្ទីរពេទ្យកុមារអង្គរបានបំបែកកំណត់ត្រារបស់ខ្លួនក្នុងការអនុវត្តតាមបទដ្ឋានអនាម័យដៃ ក្នុងកម្រិតរហូតដល់ ៩៣% ក្នុងឆ្នាំ២០២០។

## Hand hygiene levels at their highest

In a year where Infection Prevention and Control (IPC) was paramount, AHC departments marked a record-breaking 93% compliance to hand hygiene standards in 2020

## កាត់បន្ថយពេលវេលារង់ចាំ

ពេលវេលារង់ចាំមានសារៈសំខាន់ខ្លាំងណាស់ទៅលើបទពិសោធន៍ទាំងមូលរបស់អ្នកជំងឺ និងអាចជាកត្តារាំងស្ទះដល់ការទទួលបានការថែទាំសុខភាព។ ដោយសារចំនួនអ្នកជំងឺដែលមកកាន់ផ្នែកពិគ្រោះជំងឺក្រៅនៃមន្ទីរពេទ្យកុមារអង្គរមានចំនួនតិចជាងមុន ពេលវេលារង់ចាំជាមធ្យមបានធ្លាក់ចុះមកកម្រិតទាបបំផុតគឺ៖ ១៦៧នាទី។

## Dramatically reduced waiting time

Waiting time has a significant impact on patients' overall experience and can act as a barrier to care. As a consequence of the pandemic, there were fewer patients visiting AHC for outpatient care. Thus, the average waiting time in AHC's Outpatient Department recorded its lowest time on-record: 167 minutes.



# សូចនាករនៃការអនុវត្តការងារ

# Key Performance Indicators

### ការចម្លងរោគក្នុងមន្ទីរពេទ្យទាបជាងកម្រិតមធ្យម

នៅក្នុងមន្ទីរពេទ្យកុមារអង្គរ ការចម្លងរោគជាមធ្យមមានកម្រិត ៦.១ ក្នុងចំនួនអ្នកជំងឺ ១០០០គ្រែដែលនេះ គឺមានកម្រិតទាបជាងអត្រាជាមធ្យមនៅក្នុងប្រទេសអភិវឌ្ឍន៍។

### Healthcare-associated infections (HCAI) below average

An average of 6.1 infections per 1,000 bed days placed AHC's HCAI rate lower than the average developed country.

### ការបោះពុម្ពផ្សាយចំនួន ១៣ច្បាប់លើទិនានុប្បវត្តិឈានមុខ

មន្ទីរពេទ្យកុមារអង្គរមានគោលបំណងប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍របស់ខ្លួនក្នុងនាមជាអង្គការសុខភាពកុមារឈានមុខមួយនៅក្នុងតំបន់ដែលមានធនធានទាប ដើម្បីជាសម្លេងនៅក្នុងឆាកអន្តរជាតិស្តីពីសុខភាពកុមារទូទាំងពិភពលោក។ នៅឆ្នាំ២០២០ មន្ទីរពេទ្យកុមារអង្គរបានចូលរួមចំណែកក្នុងការបោះពុម្ពផ្សាយចំនួន ១៣ច្បាប់ដល់ទស្សនាវដ្តី និងសារព័ត៌មានដៃគូ។

### 13 publications in premier journals

AHC aims to utilise our insight and experience as a leading child health organisation in a low-resource setting to influence the larger global child health conversation. In 2020, AHC contributed 13 publications to peer-reviewed journals.

### កំណើនអត្រានៃការវិលត្រឡប់មកមន្ទីរពេទ្យ

មន្ទីរពេទ្យកុមារអង្គរវាស់ស្ទង់អត្រានៃការវិលត្រឡប់មកមន្ទីរពេទ្យវិញ ដើម្បីធានាពីគុណភាពនៃការគ្រប់គ្រង និងប្រសិទ្ធិភាពនៃការថែទាំ ព្រមទាំងជាជំនួយក្នុងការរៀបចំរបាយការណ៍អំពីការអនុវត្តការងារ។ ក្នុងឆ្នាំ២០២០ អត្រាវិលត្រឡប់មកវិញមានចំនួន ០.៧%។

### Readmission rate

AHC measures readmission rates to ensure quality management and effective care was delivered, and to aid in performance reporting. In 2020, the rate was 0.7% representing a slight increase on the prior year but well below quality target of 1%.



# ជម្នះបញ្ហាលំបាក

ក្នុងឆ្នាំ២០២០ ផលប៉ះពាល់ដោយប្រយោលនៃជំងឺរាតត្បាតនេះបានជ្រៀតចូលក្នុងសកម្មភាពការងារ របស់មន្ទីរពេទ្យកុមារអង្គរ។

# Overcoming Adversity

**In 2020, the indirect impacts of the pandemic permeated our work.**

# ជម្នះបញ្ហាលំបាក
# Overcoming Adversity

ក្នុងខណៈពេលដែលប្រទេសកម្ពុជាមានសំណាងល្អបានគេចផុតពីជំងឺរាតត្បាតនេះដោយមិនទទួលរងឥទ្ធិពលធ្ងន់ធ្ងរ ផលប៉ះពាល់ដោយប្រយោលនៃជំងឺកូវីដ១៩ បានក្លាយទៅជាកត្តាដ៏គួរឱ្យព្រួយបារម្ភខ្លាំងបំផុតមួយ។

ការរាតត្បាតនៃជំងឺនេះ  បានបំផ្លិចបំផ្លាញវិស័យទេសចរណ៍ សំណង់ និងផលិតកម្មនាំចេញដែលវិស័យទាំងនោះគឺជាកត្តាជម្រុញសេដ្ឋកិច្ចប្រទេសកម្ពុជា។ ការងាររាប់រយពាន់កន្លែងត្រូវបាន បាត់បង់។ អត្រានៃភាពក្រីក្រត្រូវបានកំណត់ថាមានចំនួនកើនឡើងទ្វេរដង។

ក្នុងរយៈពេលត្រឹមតែប៉ុន្មានខែប៉ុណ្ណោះនៃការរីករាលដាលនៃជំងឺនេះជាសកល ការធ្លាក់ចុះនៃសេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមមានផលប៉ះពាល់ដល់សុខុមាលភាពកុមារ។
ភាពភ័យខ្លាចនៃការឆ្លងជំងឺបានជម្រុញឱ្យមានការគេចវេះវេស ឬពន្យារពេលនៅក្នុងការស្វែងរកសេវាថែទាំសុខភាព ដែលជាមូលហេតុធ្វើឱ្យអាការៈជំងឺកាន់តែធ្ងន់ធ្ងរឡើង។ បញ្ហានេះត្រូវបានបង្ហាញតាមរយៈតួលេខឡើងចុះនៃការមកពិនិត្យជំងឺនៅផ្នែកពិគ្រោះជំងឺក្រៅរបស់មន្ទីរពេទ្យ ក៏ប៉ុន្តែអ្នកជំងឺសម្រាកពេទ្យមានចំនួនថេរ និងកើនឡើង។

ការសម្រាកពេទ្យទាំងនេះ គឺរួមមាននៅក្នុងផ្នែកជំងឺធ្ងន់កុមារ ផ្នែកជំងឺទារក  និងផ្នែកជំងឺសម្រាកពេទ្យនៃមន្ទីរពេទ្យកុមារអង្គរ ដែលនៅតែមានចំនួនអ្នកជំងឺកុមារពេញដែលរងគ្រោះដោយសារជំងឺធ្ងន់ធ្ងរ និងគម្រាមកំហែងដល់អាយុជីវិតជាច្រើនប្រភេទ ឬក៏ត្រូវការការវះកាត់បន្ទាន់ និងការថែទាំរបួស។

សម្រាប់កុមារដែលត្រូវការការព្យាបាលជាប្រចាំសម្រាប់ជំងឺរ៉ាំរ៉ៃ ក្រុមវេជ្ជបណ្ឌិត និងគិលានុបដ្ឋាករបស់យើងបានមើលឃើញថាអ្នកជំងឺបានខកខានការណាត់ជួបតាមកាលកំណត់  ហើយបានត្រឡប់មកកាន់មន្ទីរពេទ្យកុមារអង្គរនៅពេលក្រោយមកទៀតក្នុងស្ថានភាពជំងឺធ្ងន់ធ្ងរដែលស្ថានភាពនេះអាចបង្ការជាមុនបាន។

ចំណែកឯនៅក្នុងផ្នែកជំងឺសម្រាកពេទ្យ តម្រូវការនៃការថែទាំមានភាពច្បាស់លាស់។ យើងបានទទួលកុមារចំនួន ៣១នាក់ ដែលត្រូវការចំណាយពេលលើសពី ១០០ថ្ងៃ សម្រាប់ការព្យាបាលនៅក្នុងមន្ទីរពេទ្យ។

នៅក្នុងប្រទេសដែលមានកម្រិតប្រាក់ចំណូលទាបជាច្រើន ហានិភ័យនៃវិបត្តិសុខភាពអាចក្លាយទៅជាវិបត្តិស្រេកឃ្លាន។ ក្រុមគ្រួសារមួយចំនួនត្រូវបានបង្ខំឱ្យធ្វើការសម្រេចចិត្តលើការចំណាយសម្រាប់អាហារ និងការថែទាំវេជ្ជសាស្រ្ត។

ជាលទ្ធផល បុគ្គលិកមន្ទីរពេទ្យបានកត់សម្គាល់ឃើញពីការកើនឡើងជាលំដាប់នៃចំនួនកុមារដែលរងគ្រោះដោយសារជំងឺកង្វះអាហារូបត្ថម្ភ។ ជាមួយនឹងការប៉ាន់ប្រមាណថាសមាជិកគ្រួសារប្រមាណ ៦៥% បានបង្ខំចិត្តកាត់បន្ថយការចំណាយលើអាហារដោយសារតែការបាត់បង់ប្រាក់ចំណូល ឬប្រភពចំណូល។ មន្ទីរពេទ្យកុមារអង្គរបានមើលឃើញពីឥទ្ធិពលនេះ៖ ការកើនឡើង ១ភាគ៣ នៃចំនួនកុមារដែល រងគ្រោះដោយសារជំងឺកង្វះអាហារូបត្ថម្ភ។

While Cambodia fortunately escaped the year without a full outbreak, the downstream impacts of COVID-19 had a significant impact on AHC and the families we serve.

The pandemic ravaged the tourism, construction, garment and manufacturing export sectors that prop up Cambodia's economy. Hundreds of thousands of jobs were eliminated. The poverty rate was set to double.

Just months into the global outbreak, Cambodia's economic contraction began impacting child health.

Fear of catching the virus resulted in avoidance of or delay in seeking care, eventually requiring more intensive care for advanced conditions. The story, told through numbers, showed fluctuations in outpatient visits, but stable and increased numbers for inpatient care. This included AHC's Paediatric Intensive Care Unit, Neonatal Unit and Inpatient Departments, which remained at full capacity treating children suffering from a range of life-threatening infectious diseases, or requiring emergency surgery and trauma care.

For children who required regular care for chronic conditions, our doctors and nurses saw patients missing their scheduled appointments, to later arrive at AHC in serious conditions that could have been prevented.

And in our inpatient departments, the need for our care was apparent. We recorded 26 children who spent more than 100 days at AHC throughout the year, meaning many nights slept at the hospital by patient and caregiver, coupled with the travel between their homes across Cambodia and the hospital.

As in many other low-income countries, the health crisis risks can become a hunger crisis. Families were forced to make difficult decisions about spending on food and medical care.

As a result, hospital staff recorded steady increases in the number of children suffering from malnutrition. With an estimated 65% of households forced to reduce food consumption due to income loss, AHC saw the effects: a one-third increase in the number of children suffering from malnutrition.





យើងបានឆ្លើយតបដោយកំណត់អាទិភាពលើអាហារូបត្ថម្ភកុមារឱ្យបានសមស្រប។ ក្រុមការងារផ្នែកអាហារូបត្ថម្ភបានផ្តោតលើការបង្កើនកម្រិតជំនាញ និងរំលឹកចំណេះដឹងផ្នែកអាហារូបត្ថម្ភដល់បុគ្គលិកមន្ទីរពេទ្យកុមារអង្គរទាំងអស់។ ឳពុកម្ដាយ និងអ្នកថែទាំអ្នកជំងឺទាំងអស់ដែលបានមកមន្ទីរពេទ្យកុមារអង្គរ បានទទួលការអប់រំអំពីចំណេះដឹងផ្នែកអាហារូបត្ថម្ភល្អបំផុត ការចម្អិនអាហារមានជីវជាតិ ការប្រឹក្សាអំពីការបំបៅដោះ និងចំណេះដឹងបន្ថែមអំពីការចិញ្ចឹមកូនដោយរួមទាំងចំណេះដឹងអំពីការបង្ការជំងឺបង្កដោយវីរុស និងសារៈសំខាន់នៃការអនុវត្តន៍អនាម័យស្អាត។

យើងបានប្រើប្រាស់វិធានការពង្រឹង និងតាមដានការបង្ការ និងត្រួតពិនិត្យការចម្លងរោគយ៉ាងហ្មត់ចត់នៅក្នុងមន្ទីរពេទ្យទាំងមូលដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយការចម្លងជំងឺណាមួយនៅក្នុងមន្ទីរពេទ្យ ហើយជាលទ្ធផល យើងបានទទួលកម្រិតអនុវត្តន៍ការលាងសម្អាតដៃដ៏ខ្ពស់បំផុតមួយសម្រាប់មន្ទីរពេទ្យកុមារអង្គរនោះគឺ ៩៣%។

យើងបន្តផ្តល់ការព្យាបាលដល់កុមារសម្រាប់ជំងឺងាយរងគ្រោះបំផុតដូចជា អ្នកជំងឺមហារីក ទារកកើតមិនគ្រប់ខែ និងអ្នកជំងឺដែលមានលក្ខខណ្ឌជំងឺធ្ងន់ធ្ងរផ្សេងទៀត។ កុមារដែលមិនអាចទទួលបានការព្យាបាលនៅកន្លែងផ្សេងទៀត ដោយសារតែវិបត្តិនៃជំងឺរាតត្បាត ឬហេតុផលផ្សេងៗទៀត មិនត្រូវបានបដិសេដក្នុងការពិនិត្យព្យាបាលនៅមន្ទីរពេទ្យកុមារអង្គរឡើយ។

We responded by prioritising proper child nutrition. The nutrition team focused on upskilling and refreshing nutrition knowledge of all AHC staff. Every patient and caregiver that visited AHC was to be given the best nutrition education, cooking demos, breastfeeding counselling, and complementary feeding knowledge possible – along with education about virus prevention and the importance of good hygiene practices.

We employed strict Infection, Prevention and Control (IPC) monitoring and enforcement throughout the hospital, designed to reduce the spread of any infection – and earning one of the highest hand hygiene compliance levels (93%) AHC has ever recorded.

We continued to treat the most vulnerable: cancer patients, babies born premature, and those with other underlying conditions. Any child who could not access treatment elsewhere – as a result of the pandemic or otherwise – was not denied care.

**ក្នុងខណៈពេលដែលសកម្មភាពការងារមួយចំនួនរបស់មន្ទីរពេទ្យកុមារអង្គរត្រូវបានផ្អាកដំណើរការ បញ្ហាលំបាកទាំងនេះមិនបានបញ្ឈប់បេសកកម្មរបស់យើងនោះទេ។ ជាការពិត ការខិតខំប្រឹងប្រែងរបស់យើងត្រូវបានពង្រឹងឱ្យកាន់តែខ្លាំងក្លាឡើងដោយការប្រឈមនឹងបញ្ហាលំបាកទាំងនេះ។**

ទោះបីជាគ្មានបុគ្គលិកបម្រើការងារស្ម័គ្រចិត្តដោយផ្ទាល់នៅមន្ទីរពេទ្យក៏ដោយ បុគ្គលិករបស់យើងបានស្វែងរកវិធីសាស្រ្តថ្មី ដើម្បីសិក្សា និងសម្របសម្រួលដល់ការបម្រើការងារដោយស្ម័គ្រចិត្តតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ការអប់រំបន្តក្នុងវិជ្ជាជីវៈថែទាំ និងព្យាបាល។ និស្សិត និងមន្ត្រីសុខាភិបាលបានចាប់ផ្តើមបន្តការសិក្សារបស់ពួកគេវិញ បន្ទាប់ពីរយៈពេល១ឆ្នាំ នៃការរអាក់ខានដោយសារជំងឺកូវីដ១៩។

នៅក្នុងសហគមន៍ ក្រុមការងារសហគមន៍របស់មន្ទីរពេទ្យ ក្រៅមន្ទីរពេទ្យបានចាប់ផ្តើមបន្តចុះអនុវត្តសកម្មភាពអប់រំនៅតាមតំបន់ដាច់ស្រយាលដើម្បីផ្តល់ចំណេះដឹងក្នុងការលាងសម្អាតដៃ និងការការពារជំងឺកូវីដ១៩ ការបង្ហាញណែនាំពីរបៀបចំអិន អាហារ និងអប់រំពីអាហារូបត្ថម្ភបន្ទាប់ពីសកម្មភាពសហគមន៍ត្រូវបានផ្អាកមួយរយៈខ្លីដែលបណ្តាលមកពីជំងឺកូវីដ១៩។ ដើម្បីចូលរួមចំណែកគាំទ្រក្រុមគ្រួសារអ្នកជំងឺក្នុងកំឡុងពេលដ៏លំបាកនេះ មន្ទីរពេទ្យកុមារអង្គរបានផ្តល់ជំនួយហិរញ្ញវត្ថុដល់ក្រុមគ្រួសារអ្នកជំងឺប្រមាណ ២ ០០០ គ្រួសារ នៅក្នុងមន្ទីរពេទ្យ និងបានផ្តល់ការអប់រំអំពី ការពារសុខភាពដល់ប្រជាជនតាមបណ្តាភូមិក្នុងតំបន់ដាច់ស្រយាលប្រមាណ ១៨ម៉ឺននាក់ ។ ក្នុងខែបន្តបន្ទាប់មក យើងបានសង្កេតឃើញពីភាពប្រសើរឡើងគួរឲឱ្យកត់សម្គាល់នៃអនាម័យផ្ទាល់ខ្លួននៅក្នុងសហគមន៍។

កម្មវិធី "សង្គ្រោះជីវិតទារក" បានបំពេញការងារក្នុងរយៈពេលពេញ ២ឆ្នាំក្នុងការបង្កើតជាកម្មវិធីគម្រូសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវអត្រាមរណៈភាពលើកុមារនៅក្នុងខេត្តដែលរងគ្រោះខ្លាំងជាងគេនៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ យើងបានបង្កើតប្រព័ន្ធបណ្តុះបណ្តាលស្តីពីការសង្គ្រោះទារក (BaRT) ប្រកបដោយភាពច្នៃប្រឌិត និងនិរន្តរភាព ដែលជាដំណោះស្រាយតាមបែបឌីជីថល ដើម្បីកាត់បន្ថយអត្រាមរណភាពទារកដោយសារការស្លាប់ទាក់ទងនឹងបញ្ហាផ្លូវដង្ហើម។

នៅក្នុងខែតុលា យើងសម្រេចបានភាពជោគជ័យដ៏ធំអស្ចារ្យមួយជាមួយនឹងការិយាល័យស្រាវជ្រាវវេជ្ជសាស្រ្ត Oxford ប្រចាំនៅកម្ពុជា (COMRU) ដោយបានបោះពុម្ពផ្សាយទិនានុប្បវត្តិទី១០០ របស់ខ្លួន ដែលមានការទទួលស្គាល់ពីអ្នកជំនាញ និងបង្ហាញពីការពង្រឹងការប្តេជ្ញាចិត្តរបស់យើងលើការបង្កើនការថែទាំសុខភាពកុមារនៅក្រៅទីតាំងមន្ទីរពេទ្យកុមារអង្គរផ្ទាល់។

**While some of AHC's activities paused, the year's challenges did not halt our mission. In fact, our efforts were reinforced by the adversities we encountered.**

Without in-person volunteering, our staff found new approaches, explored online avenues, and optimised virtual volunteering for continuing medical and nursing education. Students and government healthcare workers have returned to resume education, after a year of interruptions due to COVID-19.

In the community, our outreach team resumed visiting rural villages to provide hand hygiene and COVID-19 prevention education, host cooking demonstrations and deliver nutrition education, after a brief hiatus in outreach operations caused by COVID-19. To support families through this difficult period, AHC has provided financial assistance to over 2,000 families in-hospital, and visited over 180,000 people in their rural villages to deliver preventative healthcare education. In the months that followed, we saw a marked improvement in personal hygiene in the community.

Our Saving Babies' Lives programme celebrated two years of work towards creating a blueprint for improving neonatal mortality in Cambodia's most vulnerable province. After two years, the team have collected 10,000 baby surveys of pregnancy and birth information to better understand the needs of neonatal care in the province. Alongside it, we launched the innovative and sustainable Baby Resuscitation Training system (BaRT), a digital solution designed to reduce neonatal mortality due to breathing-related deaths.

In October, we achieved a major milestone alongside COMRU (the Cambodia-Oxford Medical Research Unit), publishing our 100th peer-reviewed journal paper – a reinforcement to our commitment to advancing child health beyond AHC's own walls.









# សម្លេងនៃភាពរឹងមាំ

ទឹកមុខ សម្លេង និងរឿងរ៉ាវរបស់អ្នកជំងឺ បុគ្គលិក និងអាណាព្យាបាល គឺប្រាប់អំពីរឿងរ៉ាវ និងសមិទ្ធផលរបស់មន្ទីរពេទ្យកុមារអង្គរទាំងនៅក្នុងមន្ទីរពេទ្យ សហគមន៍ និងកន្លែងផ្សេងៗទៀត។

# Stories of Resilience

**Within our hospital walls, in the community, and beyond, it's the faces, voices and stories of our patients, staff and families that tell the year's stories and impact.**



“Most of the patients we see have chronic illness so they need to visit AHC regularly for treatment. But their care is a full time job, the parents sacrifice a lot of their time and money to look after their child.”

“In our country there are many children who have trouble breathing and as a respiratory specialist I have the power to help them. I can see as an organisation, and as a country, we need to continue improving our care so we can keep treating these children.”

**Dr Um Khemuoy**
AHC Respiratory Specialist Doctor

# វេជ្ជបណ្ឌិត **អ៊ុំ គឹមមួយ**
វេជ្ជបណ្ឌិតឯកទេសផ្នែកផ្លូវដង្ហើម
នៃមន្ទីរពេទ្យកុមារអង្គរ

# Dr Um Khemuoy:
## AHC Respiratory Specialist Doctor

“អ្នកជំងឺភាគច្រើនដែលយើងបានពិនិត្យ គឺមានជំងឺរ៉ាំរ៉ៃ ដូច្នេះហើយពួកគេត្រូវមកកាន់មន្ទីរពេទ្យជាប្រចាំដើម្បីទទួលការព្យាបាល ។ ការមើលថែទាំកុមារ គឺជាការងារពេញម៉ោងដូច្នេះអាណាព្យាបាលរបស់កុមារត្រូវលះបង់ពេលវេលា និងថវិកាជាច្រើនដើម្បីមើលថែទាំកូនៗរបស់ពួកគេ។”

“នៅក្នុងប្រទេសកម្ពុជា មានកុមារជាច្រើននាក់ដែលមានបញ្ហាផ្នែកផ្លូវដង្ហើម។ ក្នុងនាមជាវេជ្ជបណ្ឌិតឯកទេសជំងឺផ្លូវដង្ហើមមួយរូប ខ្ញុំមានជំនាញដើម្បីអាចជួយពួកគេបាន។ ខ្ញុំមើលឃើញថាក្នុងតួនាទីជាអង្គភាពមួយ និងជាប្រទេសមួយ យើងចាំបាច់ត្រូវបន្តធ្វើ ឱ្យប្រសើរឡើងនូវជំនាញនៃការថែទាំរបស់យើង ដូច្នេះ យើងអាចបន្តផ្តល់ការព្យាបាលដល់កុមារទាំងនេះបានជានិច្ច។”

**វេជ្ជបណ្ឌិត អ៊ុំ គឹមមួយ**
វេជ្ជបណ្ឌិតឯកទេសផ្នែកផ្លូវដង្ហើម
នៃមន្ទីរពេទ្យកុមារអង្គរ។

ការព្យាបាលជំងឺផ្លូវដង្ហើម គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ១៩។ អ្នកជំងឺដែលមានហានិភ័យនៃការរងគ្រោះដោយសារប្រព័ន្ធផ្លូវដង្ហើម អាចនឹងប្រឈមមុខកាន់តែខ្ពស់ចំពោះវីរុសកូរ៉ូណាប្រសិនបើមានការរាតត្បាតនៃវីរុសនេះ។

Respiratory care is essential during the COVID-19 pandemic for at risk patients whose already vulnerable respiratory system would be overwhelmed by the coronavirus if they were to catch the virus.




# សង្ហារ

## អ្នកជំងឺមហារីក នៅមន្ទីរពេទ្យកុមារអង្គរ

# Sanga:

## AHC Oncology Patient

“កូនខ្ញុំបាក់ទឹកចិត្តខ្លាំងណាស់ក្នុងពេលនេះ។ និយាយរួមទៅ ខ្ញុំមានការពិបាកចិត្តខ្លាំងណាស់នៅពេលដែលឃើញកូនខ្ញុំក្លាយទៅជាស្គមស្គាំង និងទន់ខ្សោយ។ ខ្ញុំដឹងថាការព្យាបាលនៅសល់វែងឆ្ងាយទៀតក៏ប៉ុន្តែខ្ញុំឃើញអាការៈកូនខ្ញុំកែប្រែទៅជាល្អច្រើនណាស់។ ដោយសារតែការព្យាបាលនេះ កូនខ្ញុំអាចក្លាយជាក្មេងដូចគេដូចឯងឡើងវិញ។”

**អ្នកស្រីដារី**
ម្តាយរបស់សង្ហារ

សង្ហារ គឺជាកុមារាអាយុ៣ឆ្នាំ មកពីខេត្តកំពត ត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យកុមារអង្គរនៅថ្ងៃចុងក្រោយនៃឆ្នាំ២០១៩ ដោយសារជំងឺមហារីកជាលិកាគ្រាប់ឈាម (acute lymphoblastic leukemia) ។

កុមាររូបនេះក្នុងចំណោមកុមារ ២៦នាក់ផ្សេងទៀត បានសម្រាកព្យាបាលក្នុងរយៈពេលលើសពី ១០០ថ្ងៃ នៅមន្ទីរពេទ្យកុមារអង្គរ ដោយមានម្តាយជាអ្នកមើលថែក្នុងអំឡុងពេលនោះ។

ការព្យាបាលដោយប្រើប្រាស់ថ្នាំគីមីសម្រាប់សង្ហារ ធ្វើឲ្យកុមារារូបនេះវិលមុខខ្លាំង ស្រកទម្ងន់ ដេកមិនល្អ និងជ្រុះសក់ជាលំដាប់ ដែលបញ្ហាទាំងអស់នេះមានលក្ខណៈកម្រសម្រាប់ការព្យាបាលប្រភេទនេះ។

Sangha, a 3-year-old boy from Kampot province, was admitted to AHC on the last day of 2019 with ALL (acute lymphoblastic leukemia). He was to spend more than 100 days at AHC with his mother over the course of 2020, one of 26 children to do so.

Sangha’s chemotherapy treatment caused him severe bouts of nausea, weight loss, trouble sleeping, and eventual loss of his hair, which is rare for this form of chemotherapy treatment.

Sangha has now entered the final stage of treatment with a promising prognosis.

# អក្ខរា
## អ្នកម្ដាយទារកទើបកើត

# Akara:
## Mother of a Newborn at AHC

“ខ្ញុំទន្ទឹងរង់ចាំថានឹងនាំកូនស្រីរបស់ខ្ញុំទៅផ្ទះវិញឆាប់ៗ។ ខ្ញុំសង្ឃឹមថាកូនរបស់ខ្ញុំនឹងបន្តធំធាត់ និងមានសុខភាពល្អប៉ុន្តែខ្ញុំក៏មានការព្រួយបារម្ភខ្លាំងណាស់ដែរ អំពីអនាគតរបស់កូនស្រីខ្ញុំនៅក្នុងអំឡុងពេលនេះ។”

**អក្ខរា**
អ្នកម្ដាយទារកទើបកើត

អក្ខរា គឺអ្នកម្ដាយថ្មីថ្មោងមួយរូប មានអាយុ២១ឆ្នាំ។ នាងបានចំណាយពេលជាង ២៥ថ្ងៃ នៅមន្ទីរពេទ្យកុមារអង្គរ រង់ចាំមើលកូនស្រីដែលទើបកើតរបស់នាងមានសុខភាពល្អឡើងវិញនៅក្នុងផ្នែកជំងឺទារក បន្ទាប់ពីបានសម្រាលមុនពេលកំណើត។ ក្នុងអំឡុងពេលនេះ នាងបានបាត់បង់ការងារនៅហាងលក់រុក្ខជាតិមួយកន្លែង ស្របពេលដែលសមាជិកគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់នាងក៏បាត់បង់ការងារដោយសារតែវិបត្តិនៃជំងឺកូវីដ១៩ នាពេលបច្ចុប្បន្ននេះដែរ។

Akara, a 21-year-old first-time mother, spent more than 25 days at AHC, waiting for her newborn daughter to get healthy in AHC's NICU after being born premature. During this time, she had lost her job working at a local plant nursery, joining the list of her family members, friends, and neighbours who were all out of work due to the current global pandemic.



“I am looking forward to hopefully taking my daughter home soon. I hope she will continue growing and becoming healthy, but I am worried about what the future holds for my child during these times.”

**Akara**
Mum




> “Despite the virus, babies are still being born. When mothers arrive at the hospital they are very worried. Some mothers have just given birth to a seriously ill baby. Some have travelled hundreds of kilometres on the back of a motorbike with their sick baby in their arms. Now on top of that, they are nervous about the spread of the virus.”
>
> **Chea Phal**
> **AHC Neonatal Nursing Unit Manager**

# លោក ជា ផល
## ប្រធានផ្នែកថែទាំនៃអគារទារក មន្ទីរពេទ្យកុមារអង្គរ

# Chea Phal:
## AHC Neonatal Nursing Unit Manager

> “ទោះបីជាមានជំងឺរាតត្បាតក៏ដោយ ទារកគឺនៅតែកំពុងត្រូវបានសម្រាល។ នៅពេលអ្នកម្តាយមកដល់មន្ទីរពេទ្យ ពួកគាត់មានការព្រួយបារម្ភខ្លាំងណាស់។ អ្នកម្តាយខ្លះ ទើបតែផ្តល់កំណើតដល់ទារកដែលមានជំងឺធ្ងន់ធ្ងរ។ ខ្លះទៀតបានធ្វើដំណើរក្នុងចម្ងាយរាប់រយគីឡូម៉ែត្រនៅលើម៉ូតូដោយបីកូននៅក្នុងដៃ។ បន្ថែមពីលើនេះទៀត ពួកគេភ័យខ្លាចពីការរីករាលដាលនៃជំងឺកូវីដ១៩ផងដែរ។”
>
> លោក ជា ផល
> ប្រធានផ្នែកថែទាំនៃអគារទារក មន្ទីរពេទ្យកុមារអង្គរ

លោក ជា ផល ដែលបានសង្កេតឃើញពីកំណើននៃចំនួនអ្នកជំងឺនៅក្នុងផ្នែកជំងឺធ្ងន់ទារកបានទទួលអ្នកជំងឺទារក លើសចំនួនកំណត់នៅក្នុងខែមេសា និងឧសភា។

លោក ជា ផល និងបុគ្គលិកគិលានុបដ្ឋាកផ្សេងទៀតផ្តល់ការអប់រំអំពីជំងឺកូវីដ១៩ ជាប្រចាំសម្រាប់ក្រុមអ្នកម្តាយដែលពួកគេជាច្រើនសម្រាកនៅក្នុងមន្ទីរពេទ្យជាច្រើនសប្តាហ៍រង់ចាំមើលកូនៗរបស់គេជាសះស្បើយឡើងវិញ។

Chea Phal saw the rise in patient numbers in his department. The NICU was near capacity throughout April and May.

Phal and AHC’s nurses hold regular COVID-19 educational sessions for mothers, many of whom stay at the hospital for weeks at a time, waiting for their baby to get well.

# វេជ្ជបណ្ឌិត ងួន ច័ន្ទភក្រ្តា

នាយកមន្ទីរពេទ្យកុមារអង្គរ

# Dr Ngoun Chanpheaktra:

## AHC Hospital Director

“ វាគឺជាឆ្នាំដ៏លំបាកមួយនៅពេលដែលមើលឃើញអាណាព្យាបាលកុមារមកដល់មន្ទីរពេទ្យក្នុងស្ថានភាពគួរឱ្យសោកសង្រេងជាខ្លាំង។ ប៉ុន្តែយើងដឹងថាយើងមានជំនាញដើម្បីជួយក្រុមគ្រួសារទាំងនោះ និងកូនៗរបស់ពួកគេដូចដែលយើងធ្លាប់បានធ្វើអស់រយៈពេលច្រើនជាង ២០ឆ្នាំ កន្លងមកហើយ។ ”

លោកវេជ្ជបណ្ឌិត ងួន ច័ន្ទភក្រ្តា

នាយកមន្ទីរពេទ្យកុមារអង្គរ






# ស៊ីតា
## អ្នកដេរស្បែកជើង នៅក្នុងភូមិតារៀម

# Sita: Shoe Cobbler in Ta Ream Village

"ខ្ញុំព្យាយាមលាងសម្អាតដៃកូនរបស់ខ្ញុំឱ្យបានញឹកញាប់ ជាពិសេសនៅពេលលេងក្រៅផ្ទះ។"

**ស៊ីតា**
អ្នកដេរស្បែកជើង នៅក្នុងភូមិតារៀម

ជំងឺកូវីដ១៩ មិនបានរើសអើងរវាងអ្នកមានឬក្រឡើយ។ សហគមន៍ដាច់ស្រយាលគឺជាកន្លែងដែលរងទម្ងន់នេះធ្ងន់ជាងគេ។ ពួកគេខ្វះព័ត៌មានអំពីការអនុវត្តន៍ការលាងសម្អាតដៃ ការយល់ដឹងអំពីការឆ្លងរបស់ជំងឺកូវីដ១៩ និងចំណេះដឹងអំពីសារៈសំខាន់នៃការការពារខ្លួន និងក្រុមគ្រួសារ។

ដូចជាប្រជាជនខ្មែរជាច្រើននាក់ទៀតដែរ អ្នកស្រីរស់នៅជុំគ្នាជាមួយគ្រួសារដែលមានសមាជិកច្រើន ដែលមានភាពពិបាកក្នុងការអនុវត្តន៍គម្លាតសង្គម។ ការប្រើប្រាស់ទឹកស្អាតមានចំនួនកំណត់ មានន័យថាគ្រួសាររបស់អ្នកស្រីត្រូវប្រើជែល ឬអាល់កុលសម្អាតដៃ តែពេលដែលពួកគេមានលទ្ធភាពទិញប៉ុណ្ណោះ។

While COVID-19 does not distinguish between rich and poor, the rural communities have been the ones to bear the biggest burden. They lack essential hand hygiene information, an understanding of how the virus is transmitted, and knowledge of the importance of simple preventative measures to protect themselves and their families.

Sita, a cobbler and a mother, is concerned about protecting her children from COVID-19. Like most rural Cambodians, she shares her house with her extended family, struggling to practise safe social distancing measures. Her limited access to clean water means her family must resort to using alcohol gel to clean their hands — when they can afford it.

# សុខុម និងកូនស្រី របស់គាត់ យ៉ានិត ជាអ្នកជំងឺរ៉ាំរ៉ៃ

# Sokhom and her daughter Priyanith:
## Chronic Care Recipients at AHC

“ ខ្ញុំបានទុកកូនរបស់ខ្ញុំនៅក្នុងផ្ទះ មិនឱ្យលេងជាមួយក្មេងៗដ៏ទៃទៀតទេ។ បើជំងឺកូនខ្ញុំធ្វើទុក្ខជាថ្មីទៀត យើងចាំបាច់ត្រូវមកមន្ទីរពេទ្យ។ ”

**សុខុម**
ម្ដាយរបស់យ៉ានិត

សុខុម និងកូនស្រីរបស់គាត់ យ៉ានិត បានមកកាន់មន្ទីរពេទ្យកុមារអង្គរជាទៀងទាត់ ដើម្បីព្យាបាលជំងឺហឺតរ៉ាំរ៉ៃរបស់កូនស្រី។ ដូច ក្រុមគ្រួសារផ្សេងទៀតដែរនៅក្នុងប្រទេសកម្ពុជា គាត់គ្មានការងារតាំងពីមានជំងឺរាតត្បាតមក ដូច្នេះហើយមិនមានលទ្ធភាពគ្រប់គ្រាន់លើរ៉ាប់រងថ្លៃធ្វើដំណើរមកខេត្តសៀមរាបដើម្បីព្យាបាលបានទេ។ គាត់ត្រូវបង្ខំចិត្តពន្យារពេលការព្យាបាលរហូតដល់គាត់អស់ថ្នាំ ធ្វើឱ្យអាការៈកូនរបស់គាត់ធ្ងន់ធ្ងរជាងមុន។

តាមរយៈការអប់រំពីសារៈសំខាន់នៃការព្យាបាលជាប់លាប់លើជំងឺឯកទេស និងវគ្គបណ្ដុះបណ្ដាលការពារជំងឺកូវីដ១៩ សុខុម និងយ៉ានិតបានវិលត្រឡប់មកទទួលការព្យាបាលឯកទេសជាបន្តឡើងវិញនៅមន្ទីរពេទ្យកុមារអង្គរសម្រាប់ការព្យាបាលជំងឺផ្លូវដង្ហើមនេះ។

Sokhom and her daughter Priyanith visited AHC regularly to treat her chronic asthma. But like many parents in Cambodia, Sokhom became unemployed since the beginning of the pandemic and was unable to afford the cost of travel to Siem Reap, over three hours drive away. She was forced to delay seeking care until they ran out of medication, and her daughter's symptoms worsened.

Through education on the importance of continued care for specialty conditions, and preventative training on COVID-19, Sokhom and Priyanith have now returned to AHC to receive specialist respiratory care.



“ **I had been keeping my daughter inside, not letting her play with the other kids, in case she became sick again and we had to go to the hospital.** ”

**Sokhom**
**Priyanith's mum**




# អ្នកស្រី ស្រ៊ឺ ផាន់ស៊ី

## គិលានុបដ្ឋាកផ្នែកអាហារូបត្ថម្ភ នៃមន្ទីរពេទ្យកុមារអង្គរ

# Phannsy Sroeu:

## AHC Nutrition Nurse

“ស្ទើរតែទាំងអស់នៃកុមារ និងទារកដែលយើងសង្កេតឃើញកើតជំងឺកង្វះអាហារូបត្ថម្ភនៅក្នុងមន្ទីរពេទ្យ គឺមកពីតំបន់ភូមិដាច់ស្រយាល។ អ្នកភូមិទាំងនោះភាគច្រើន គឺមិនមានការយល់ដឹង ឬមិនមានលទ្ធភាពទិញអាហារដែលមានជីវជាតិគ្រប់គ្រាន់ដល់កូនៗរបស់ពួកគេទេ។ ហេតុដូច្នេះហើយបានជាក្រុមរបស់ខ្ញុំ និងក្រុមការងារសហគមន៍ផ្តោតលើការកសាងចំណេះដឹងដល់ពួកគេ ដើម្បីបង្ការជំងឺកង្វះអាហារូបត្ថម្ភ និងជាពិសេសនៅក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩ នេះ។”

**អ្នកស្រី ស្រ៊ឺ ផាន់ស៊ី**
គិលានុបដ្ឋាកផ្នែកអាហារូបត្ថម្ភ
នៃមន្ទីរពេទ្យកុមារអង្គរ

នៅក្នុងអគារមន្ទីរពេទ្យកុមារអង្គរ ក្រុមការងារផ្នែកអាហារូបត្ថម្ភជួបប្រទះនឹងលទ្ធផលនៃការបំបៅដោះកូនដោយមិនត្រឹមត្រូវរបស់ក្រុមគ្រួសារក្រីក្រ និងមិនមានចំណេះដឹង។ ។ នៅតាមបណ្តាភូមិនៅជុំវិញខេត្តសៀមរាប ក្រុមការងារសហគមន៍របស់មន្ទីរពេទ្យកុមារអង្គរក៏សង្កេតឃើញពីលទ្ធផលដូចគ្នានេះដែរ។

In AHC's hospital wards, the nutrition team face the result of families facing the barriers of poverty and lack of nutrition knowledge, struggling to feed their children correctly. Throughout the villages surrounding Siem Reap, AHC's community outreach team see the same.

# លោក ភឿក អមរា

## អនុប្រធានផ្នែក
## សុខភាពសហគមន៍
## នៃមន្ទីរពេទ្យកុមារអង្គរ

# Phoeurk Amra:

## Unit Manager of the AHC Community Outreach team

“

យើងទាំងអស់គ្នាត្រូវតែធ្វើការរួមគ្នាដើម្បីទប់ស្កាត់ជំងឺកូវីដ១៩ ក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភរបស់កុមារនៅក្នុងសហគមន៍។ អ្នកភូមិលាងសម្អាតដៃបានទៀងទាត់ជាងមុន និងបរិវេណនៅជុំវិញផ្ទះ ដែលជាកត្តាបញ្ឈប់ការឆ្លងនៃជំងឺកូវីដ១៩។ លើសពីនេះទៀត វាក៏បានជួយការពារជំងឺផ្សេងទៀតដែរដូចជារាគមួល និងជំងឺឆ្លងជាច្រើនទៀត។វាមានសារៈសំខាន់ណាស់ដើម្បីជួយការពារក្មេងៗពីជំងឺកង្វះអាហារូបត្ថម្ភ ។

”

**លោក ភឿក អមរា**
អនុប្រធានផ្នែកសុខភាពសហគមន៍
នៃមន្ទីរពេទ្យកុមារអង្គរ

លោក ភឿក អមរា (អនុប្រធានផ្នែកសុខភាពសហគមន៍នៃមន្ទីរពេទ្យកុមារអង្គរ)។ លោក អមរា មានការព្រួយបារម្ភអំពីផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើអាហារូបត្ថម្ភរបស់កុមារ ក៏ប៉ុន្តែគាត់បានមើលឃើញអំពីការរីកចម្រើនគួរឱ្យកត់សម្គាល់លើអនាម័យផ្ទាល់ខ្លួននៅក្នុងសហគមន៍ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះបន្ទាប់ពីបានទទួលការអប់រំអំពីការបង្ការ ជំងឺកូវីដ១៩ នេះពីមន្ទីរពេទ្យកុមារអង្គរ និងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

Phoeurk Amra is Unit Manager of the AHC Community Outreach Team. Amra is concerned about the impact COVID-19 may have on child nutrition, but he has seen a marked improvement in personal hygiene in the community, following months of COVID-19 prevention education from AHC and the Cambodian Ministry of Health.






“The physicians in Cambodia have to do more with fewer resources than what we have in the US, often solving problems without a new tool or test to help.
Next year I am hoping to fund a laparoscopy student to go anywhere in the world for training and bring someone back who can teach the AHC team the laparoscopy skills needed.”

**Dr Kevin Gandhi**
**AHC Volunteer**

# វេជ្ជបណ្ឌិត **ខេវីន ហ្គាន់ឌី**

## អ្នកស្ម័គ្រចិត្តជំងឺឯកទេសតម្រងនោម

# Dr Kevin Gandhi: Volunteer Paediatric Urologist

“គ្រូពេទ្យនៅក្នុងប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើការងារជាច្រើនដោយសារកម្រិតធនធានទាបបើប្រៀបធៀបទៅនឹងអ្វីដែលយើងមាននៅក្នុងសហរដ្ឋអាមេរិក ហើយជាញឹកញាប់ដោះស្រាយបញ្ហាដោយគ្មានឧបករណ៍ថ្មី ឬការធ្វើតេស្តជាជំនួយ។ ឆ្នាំក្រោយ ខ្ញុំសង្ឃឹមថាខ្ញុំនឹងអាចឧបត្ថម្ភនិស្សិតជំនាញផ្នែកវះកាត់ពោះមួយរូបដើម្បីឱ្យទៅសិក្សានៅប្រទេសណាមួយក្នុងពិភពលោក និងត្រឡប់មកវិញដោយនាំអ្នកជំនាញណាម្នាក់មកជាមួយដែលអាចបង្រៀនក្រុមការងារមន្ទីរពេទ្យកុមារអង្គរលើជំនាញវះកាត់ពោះដោយផ្ទះ។”

**វេជ្ជបណ្ឌិត ខេវីន ហ្គាន់ឌី**
អ្នកស្ម័គ្រចិត្តជំងឺឯកទេសតម្រង់នោម

អស់រយៈពេលជាង ១០ឆ្នាំ វេជ្ជបណ្ឌិត ខេវីន ហ្គាន់ឌី បានស្ម័គ្រចិត្តបម្រើការងារនៅមន្ទីរពេទ្យកុមារអង្គរជារៀងរាល់ឆ្នាំ ដើម្បីធ្វើការវះកាត់ដល់កុមារកម្ពុជា និងកសាងសមត្ថភាពបុគ្គលិកនៅផ្នែកវះកាត់។ លោកគ្រូគឺជាអ្នកស្ម័គ្រចិត្តមួយរូបក្នុងចំណោមអ្នកស្ម័គ្រចិត្តជាច្រើនរូបផ្សេងទៀតដែលបានជួយអភិវឌ្ឍជំនាញផ្នែកពិនិត្យព្យាបាល និងថែទាំឯកទេសកុមារនៅមន្ទីរពេទ្យកុមារអង្គរ។

ក្រោមការណែនាំពីវេជ្ជបណ្ឌិតហ្គាន់ឌី បច្ចុប្បន្ននេះ ក្រុមការងារផ្នែកវះកាត់របស់មន្ទីរពេទ្យកុមារអង្គរអាចធ្វើការវះកាត់លើជំងឺជាក់លាក់មួយចំនួនសម្រាប់កុមារកម្ពុជាដែលមិនមានលទ្ធភាពទទួលបានការព្យាបាលនៅទីកន្លែងផ្សេងទៀតនៅក្នុងប្រទេស។

Over the past decade, Dr Kevin Gandhi has volunteered at AHC every year to perform life-saving surgery on Cambodian children and build the capacity of AHC's Surgical Unit. He is one of the many volunteers helping develop AHC's paediatric subspecialty care and education curricula.

Under Dr Gandhi's skilled guidance, AHC's surgery team can now perform select surgeries for Cambodian children who cannot access treatment anywhere else in the country.

# សឹម ចាន់មេត្រី
## ឆ្មប នៅមណ្ឌលសុខភាពរវៀង

# Sim Chanmetrey:
## Midwife, Rovieng Health Centre

សឹម ចាន់មេត្រី គឺជាឆ្មបមួយរូបក្នុងចំណោមឆ្មបផ្សេងទៀត ដែលធ្វើការនៅមណ្ឌលសុខភាពរវៀង ក្នុងខេត្តព្រះវិហារ។ បច្ចុប្បន្ននេះ មេត្រីបានកំពុងសិក្សាអំពីប្រព័ន្ធ ដង្ហើមទារកឈ្មោះថា ប្រព័ន្ធ **BarT** ដែលជាប្រព័ន្ធមួយត្រូវបានណែនាំដោយក្រុមការងារសង្គ្រោះជីវិតទារក នៅមណ្ឌលសុខភាពកាលពីខែមិថុនា ឆ្នាំ២០២០។ ប្រព័ន្ធ **BarT** បង្រៀនបុគ្គលិកសុខាភិបាលពីវិធីសាស្រ្តសង្គ្រោះទារកទើបកើតតាមរយៈការវាស់វែងសម្ពាធខ្យល់ និងល្បឿនដែលបង្ហាញនៅក្នុងកម្មវិធីទូរស័ព្ទ និងផ្តល់ពួកគេនូវការឆ្លើយតបភ្លាមៗនៅពេលពួកគេកំពុងធ្វើការសង្គ្រោះទារក។

មេត្រី បានរំលឹកថា សប្តាហ៍មុននេះ គាត់បានប្រើប្រាស់ប្រព័ន្ធបណ្តុះបណ្តាល BarT នៅពេលដែលទារកម្នាក់ឈប់ដកដង្ហើមរយៈពេលខ្លីបន្ទាប់ពីកើត។

Sim Chanmetrey is one of a dozen midwives working at Rovieng Health Centre in Preah Vihear province. Recently, she has been familiarising herself with the BaRT system, which the SBL team introduced to the health centre in June 2020. BaRT teaches health workers how to resuscitate a neonate by measuring air pressure and pace delivered on an app, giving them real-time feedback when they are performing resuscitation.

Last week she had to use her BaRT training when a baby stopped breathing shortly after birth.

“ខ្ញុំបាននឹកឃើញពីការបណ្តុះបណ្តាលរបស់ខ្ញុំអំពីសម្ពាធ និងល្បឿននៃការច្របាច់ថង់ខ្យល់ និងទីតាំងត្រឹមត្រូវនៃម៉ាស់ដែលបំពាក់នៅជុំវិញមាត់របស់ទារក។ បន្ទាប់ពីច្របាច់ថង់ខ្យល់អស់រយៈពេលយូរបន្តិចមក ទារកចាប់ផ្តើមដកដង្ហើមឡើងវិញ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ដែលខ្ញុំបានធ្វើសកម្មភាពភ្លាមៗ និងដោយភាពជឿជាក់។”

**សឹម ចាន់មេត្រី**
ឆ្មបនៅមណ្ឌលសុខភាពរវៀង



“I called on my training; the pressure and the pace to squeeze the bag, and the correct position of the mask around the baby’s mouth. After squeezing the bag for some long moments, the baby started breathing again. I was pleased that I acted so quickly and confidently.”

**Sim Chanmetrey**
Midwife

# អភិបាលកិច្ច

ក្នុងខណៈពេលដែលសម្ពាធនៃវិបត្តិជំងឺរាតត្បាតបាន និងកំពុងបន្តកើតមានឡើងមកលើសុខុមាលភាពកុមារនៅក្នុងប្រទេសកម្ពុជា សេដ្ឋកិច្ចពិភពលោកក៏មានឥទ្ធិពលប៉ះពាល់មកលើសមត្ថភាពរបស់មន្ទីរពេទ្យកុមារអង្គរផងដែរក្នុងការធានាសុវត្ថិភាពនៃការស្វែងរកមូលនិធិ។

យើងត្រូវបង្ខំចិត្តបត់បែនតាមសម្ពាធនៃហិរញ្ញវត្ថុក្នុងប្រតិបត្តិការរបស់យើង ដោយរួមមានការកើនឡើងនៃតម្លៃថ្នាំ និងសម្ភារៈផ្គត់ផ្គង់ ការលុបចោលនៃព្រឹត្តិការណ៍ស្វែងរកមូលនិធិផ្សេងៗ និងការផ្លាស់ប្តូរគោលដៅមូលនិធិសប្បុរសធម៌ទៅលើការឆ្លើយតបនឹងឥទ្ធិពលនៃជំងឺកូវីដ១៩។

ជាលទ្ធផល មន្ទីរពេទ្យកុមារអង្គរបានធ្វើសកម្មភាពមួយចំនួនដើម្បីកាត់បន្ថយការធ្លាក់ចុះនៃមូលនិធិ និងបន្ធូរបន្ថយផលប៉ះពាល់នេះមកលើយុទ្ធសាស្ត្ររបស់អង្គភាព។ សកម្មភាពទាំងនេះរួមមាន វិធីសាស្ត្រសន្សំសំចៃនៅក្នុងអង្គភាពទាំងមូលក៏ប៉ុន្តែព្យាយាមរក្សាគុណភាព សេវាកម្ម ដល់អ្នកជំងឺទាំងអស់ ការពន្យារពេលនៃគម្រោងមូលធនមួយចំនួន ការប្រើប្រាស់មូលនិធិបម្រុងដើម្បីបំពេញចន្លោះប្រហោងនៃមូលនិធិ និងការប្រើប្រាស់មូលនិធិបន្ទាន់។

ទស្សនហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២១ គឺប្រាកដណាស់ថានឹងចោទជាបញ្ហាប្រឈមខ្លាំង ក៏ប៉ុន្តែយើងរក្សាស្មារតីរឹងមាំលើកិច្ចការងាររបស់យើងដើម្បីធានាលើកកម្ពស់សុខុមាលភាព កុមារមិនឱ្យធ្លាក់ចុះឡើយ។ គម្រោងថវិកាប្រតិបត្តិការប្រចាំឆ្នាំចំនួន ៥.៥លានដុល្លារអាមេរិក ត្រូវបានកំណត់សម្រាប់ឆ្នាំ២០២១ ដែលចំនួននេះឆ្លុះបញ្ចាំងអំពីយន្តការបន្តអនុវត្តវិធានការសន្សំសំចៃដែលបានធ្វើនៅក្នុងឆ្នាំ២០២០។

# Governance

Despite the increasing pressure the pandemic has had and will continue to have on child health throughout Cambodia, the global economic downturn has had an impact on AHC's ability to secure funding.

Operationally, we have been forced to adapt to financial pressures, including cost increases for medications and supplies, the cancellation of fundraising events, and a shift in philanthropic funding towards more localised COVID-19 response efforts.

As a result, AHC took a number of steps to reduce the funding shortfall and mitigate the impact of this on our organisational strategies. This included cost saving measures across the organisation while maintaining quality and service to our patients, delay of capital projects, the use of existing reserve funds to fill in a portion of the funding gap, and emergency funding.

The financial outlook for 2021 is sure to be challenging, but we remain resolute in the urgency of our work to ensure child health outcomes do not slip backwards. An operating budget of US$5.5 million has been set for 2021 which reflects a number of continued cost saving measures enacted in 2020.

មន្ទីរពេទ្យកុមារអង្គរ ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលស្ម័គ្រចិត្ត។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើការត្រួតពិនិត្យយុទ្ធសាស្ត្ររបស់មន្ទីរពេទ្យកុមារអង្គរ គ្រប់គ្រងយុទ្ធសាស្ត្រហានិភ័យ ភាពជាអ្នកដឹកនាំ និងគណនេយ្យភាព។ ដើម្បីសិក្សាស្វែងយល់បន្ថែមអំពីក្រុមប្រឹក្សាភិបាលរបស់មន្ទីរពេទ្យកុមារអង្គរ សូមចូលទៅកាន់គេហទំព័រ
**angkorhospital.org/our-board**

AHC is governed by a volunteer Board of Directors. The Board is responsible for overseeing AHC's strategy, managing strategic risk, and providing managerial leadership and accountability. To learn more about AHC's Board of Directors, visit: angkorhospital.org/our-board

## ប្រធានក្រុមប្រឹក្សាភិបាល
## Chairman of the Board
Robert Gazzi

## ក្រុមប្រឹក្សាភិបាល
## Board of Directors
Dan Simmons
Jean-Gaetan Guillemaud
Kenro Izu
Lawence Tsang
Lina Saem Stoey
Lindsay William Cooper
Lisa Genasci
Dr Nick Day
Dr Shunmay Yeung
Soum Sambath
Stuart Davy
Billy Gorter

## ក្រុមប្រឹក្សាភិបាលប្រចាំសហរដ្ឋអាមេរិក
## AHC USA Board Members
Dr Robbert Nassau
John Canan
Lisa Genasci
Chris Chapman

## ក្រុមប្រឹក្សាភិបាលប្រចាំចក្រភពអង់គ្លេស
## AHC UK Board Members
Aurore Gil
Catherine Gaynor
Denys Firth
Lisa Genasci
Dr Michael Carter
Robert Gazzi

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាល
## Board Committees
Audit & Operational Risk
Medical Education, Ethics & Oversight
Remuneration

## ក្រុមប្រឹក្សាពិគ្រោះយោបល់របស់មន្ទីរពេទ្យ
## AHC Advisory Council
Chhour Y Meang
Hun Socheat
Jay Cohen
Prof Ka Sunbaunat
Lim Kuy
H.E. Seang Nam
Dr Tia Phalla

# របាយការណ៍ហិរញ្ញវត្ថុ
# Financials

មន្ទីរពេទ្យកុមារអង្គរធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ របស់ទីក្រុងហុងកុង ហើយរបាយការណ៍ទាំងនេះត្រូវ បានធ្វើសវនកម្មដោយក្រុមហ៊ុន Baker Tilly Hong Kong។ ដើម្បីចូលមើលរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សូមចូលទៅកាន់គេហទំព័ររបស់មន្ទីរពេទ្យកុមារអង្គរ angkorhospital.org/report

### Audited Financial Statements

AHC produces annual financial statements in accordance with Hong Kong Financial Reporting Standards and these are audited by Baker Tilly Hong Kong. To see our financial statements for the year ended 31st December 2020, visit angkorhospital.org/report

## SOURCE OF FUNDS: FULL YEAR 2020




Total funds raised in 2020: **$5.7 million**

NOTE: The figures above excluding $234k donation-in-kind received from The Royal Government of Cambodia.

## USE OF FUNDS:




Total use of funds in 2020: **$6.3 million**

# សេចក្តីថ្លែងអំណរគុណ
# Thank You.

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្ត និងទឹកចិត្តសប្បុរសធម៌របស់សប្បុរសជនទាំងអស់ដែលបានបរិច្ចាគទាំងពេលវេលា និងថវិកាដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពកុមារនៅកម្ពុជា។

ក្រោមការគាំទ្ររបស់អ្នកទាំងអស់គ្នា យើងប្តេជ្ញាបន្តចូលរួមធ្វើឱ្យប្រសើរឡើងនូវការថែទាំសុខភាពសម្រាប់កុមារកម្ពុជា។ សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់ដែលបានជួយឧបត្ថម្ភដោយទឹកចិត្តដ៏សប្បុរសដល់មន្ទីរពេទ្យកុមារអង្គរ។

យើងខ្ញុំ សូមថ្លែងអំណរគុណជាពិសេស ដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ឱកាសនូវកិច្ចសហប្រតិបត្តិការ ដែលមិនអាចកាត់ថ្លៃបានជាមួយយើងខ្ញុំ នៅក្នុងការប្រតិបត្តិផ្តល់សេវាសុខភាពជូនកុមារកម្ពុជា។

ក្រសួងសុខាភិបាល
ឃ្លាំងឱសថកណ្តាល (កម្ពុជា)
មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេសដ៍ ជំងឺសើស្បែក និងជំងឺកាមរោគ
មន្ទីរពេទ្យកុមារជាតិ
មន្ទីរសុខាភិបាលខេត្តសៀមរាប
មន្ទីរពេទ្យបង្អែកខេត្តសៀមរាប
មន្ទីរសុខាភិបាលខេត្តព្រះវិហារ

We are profoundly thankful for the commitment and generosity of those who donate their time and money to improve child health in Cambodia. With you by our side, we will continue to transform paediatric healthcare in Cambodia. Thank you to all of our donors for your generous support.

A special thank you to the Royal Government of Cambodia.
We value the opportunity to work closely with the Royal Government of Cambodia, and we acknowledge their kind support.

Ministry of Health (MoH)
Central Medical Stores (Cambodia)
National Center for HIV/AIDS, Dermatology and STDs (NCHADS Cambodia)
National Paediatric Hospital Cambodia (NPH)
Siem Reap Provincial Health Department
Siem Reap Provincial Hospital
Preah Vihear Provincial Health Department

## Corporate

Advance Entrepreneurs of Battambang
Albizia Capital
Cambodia Chemical Supply Co., Ltd.
Cook Medical Australia
Danone Specialized Nutrition (Cambodia)
Easy Cash Pawn Company
hawo GmbH
Heng Development Co., Ltd
Herbalife Nutrition Foundation
Janus Henderson Foundation
K Distribution Co., Ltd.
KOOMPI
Manulife
Peng Huoth Group
PwC Charitable Foundation, Inc.
Rouy Infinity Co.Ltd
Sathapana Bank PLC
Smart Axiata Cambodia
Sokha Hotel Co., Ltd
Trip.com Cambodia
Urban Hub (Cambodia) Co., Ltd.
Vital Premium Water Company
Vitol Foundation

## Foundations & Trusts

A Drop of Life
Belgium Association
Cambodia Red Cross
Carraresi Foundation
Catholic Relief Services
Chao Foundation
CRH Charitable Trust
Daylesford Trust
FDI World Dental Association
Firetree Asia Foundation
Force for Good Foundation
Friends Without a Border
Friends Without a Border, Japan
Fu Tak Iam Foundation Limited
GHR Foundation
Heart to Heart Foundation
IF International Foundation
International Society for Children with Cancer
Leon Judah Blackmore Foundation
Lotus Foundation Cambodia
Manan Trust
Oral Health Foundation Pierre Fauchard Academy
Peter Bennett Foundation
Pignatelle Foundation
Porticus
Ptarmigan Charitable Foundation
Rosebud Foundation
SEVA Foundation
T. & J. Meyer Family Foundation Limited
The Lloyd George Asia Foundation
Third Monday Foundation
YP Foundation
Zau Foundation

## Individuals & Families

Alistair Thompson
Anonymous
Ben Hall and Shen Hsieh
Bilan Cooper Family
Dan and Mandy Simmons
Dana Stapleton
Dieter Turowski and Laura Howard
Dr Matsumi Kamachi
Ea Chiva
Edwin and Peta McAuley
Francoise and Marie Michele Turner
Fred Huston
H.E. Chhay Leakhena
H.E. Heng Sour
H.E. Hour Hub
H.E. HUN Manet and Lok Chumteav Pich Chanmony
H.E. Keo Rattanak
H.E. Khuong Sreng
Hanna Sörensson
Il Yong Jung and Sonya Kim
Ing Sotheara
James Fulton
John Canan
John Harrison
John Scott
Kathie Mundy and Fred Hessler
Kevin Kishin Gandhi
Khim Finang and Thieng Katika
Koy Lepol
Lina Saem Stoey and family
Linda Chandler
Ly Eang Hong and Chea Eam
Matthew Bording
Nikola Kemper and Damien Ryan
Oknha Cheam Khun Nath
Oknha Hong Nikolin and Ngov Pisey
Oknha Leang Khun
Oknha Ngov Sarin
Oknha Tea Vichet
Paul Bamatter
Paul Brough
Peng Sen and Ret Sarong
Pu Hean
Robert and Sue Gazzi
Robert Johnson and Trudy Chan
Samdech Kittiprittbandit Bun Rany Hun Sen
Sao Sokny
Seng Teavmeng
So Hok Long
Te Seamla
Thomas Triplett
Thu Pach
Vong Sovann
Walter Scott

## Institutional & Academic

Aiglon College
Boston Children's Hospital Global Health Program
Cambodia Oxford Medical Research Unit (COMRU)
Cambodia Youth Movement 157
Civil Society in Development (CISU)
JERUDONG INTERNATIONAL SCHOOL
Sihanouk Hospital Center of Hope
Union of Youth Federations of Cambodia (UYFC)
University of Technology Sydney (UTS

## In-Kind Donors

Eco-Soap Bank
Health Partners International Of Canada (HPIC)
National Pediatric Hospital
NCHADS
SHOFU Dental Asia-Pacific Pte. Ltd.

## Events & Virtual Fundraisers

AHC Rouleurs
Catherine Scott
Kong Boeb and Dom Ros
Lawrence Tsang
Luk Sovanna
Martin and Vanessa Wynne
Rifle Range Riders
Ross Pienaar
Simmons Family
Wing (Cambodia) Ltd Specialised Bank

សូមសប្បុរសជនទាំងអស់មេត្តាអធ្យាស្រ័យនូវការដែលមិនបានរាយនាមសប្បុរសជនទាំងអស់នៅក្នុងរបាយការណ៍នេះទេ។ ខាងក្រោមនេះ គឺជាបញ្ជីរាយនាមសប្បុរសជនដែលបានឧបត្ថម្ភគាំទ្រដល់មន្ទីរពេទ្យកុមារអង្គរ ចាប់ពី ២ ៥០០ ដុល្លារអាមេរិកឡើងទៅ។

We couldn't list all of our generous donors within this report. Donors contributing US $2,500 or more are included in this list.